# ឧបករណ៍បង្កើនសំទុះ Large Hadron Collider ( 10 points )

សូមអានការណែនាំទូទៅមុននឹងចាប់ផ្តើមធ្វើលំហាត់។

ក្នុងលំហាត់នេះរូបវិទ្យានៃឧបករណ៍បង្កើនសំទុះផង់ LHC ( Large Hadron Collider ) នៅទីពិសោធន៍ CERN ត្រូវបានពិភាក្សា។

CERN គឺជាទីពិសោធ៍រូបវិទ្យាផង់ធំបំផុតលើពិភពលោក។ គោលបំណងសំខាន់គឺបង្ហាញអោយឃើញច្បាប់គ្រឹះនៃធម្មជាតិ។ បាច់ពីរនៃផង់ត្រូវបានបង្កើនសំទុះអោយមានថាមពលខ្ពស់ ដោយដែនម៉ាញ៉េទិចខ្លាំង ហើយវាទង្គិចគ្នាទៅវិញទៅមក។ ប្រូតុងមិនបានរាយស្មើសាច់នៅជុំវិញបរិមាត្រនៃឧបករណ៍បង្កើនសំទុះទេ ប៉ុន្តែវាបានផ្តុំគ្នាជាបណ្តុំ។ ជាលទ្ធផលផង់ដែលកើតឡើងដោយទង្គិចនេះ ត្រូវបានសង្កេតដោយឧបករណ៍ចាប់សញ្ញាធំមួយ (large detectors )។ ប៉ារ៉ាម៉ែតមួយចំនួននៃ LHC អាចរកបានក្នុង table 1។

| | |
|---|---|
| វង់ LHC | |
| បរិមាត្រនៃវង់ Circumference of ring | $26659\ \mathrm{m}$ |
| ចំនួនបណ្តុំក្នុងមួយបាច់ប្រូតុង Number of bunches per proton beam | $2808$ |
| ចំនួនប្រូតុងក្នុងមួយបណ្តុំ Number of protons per bunch | $1.15 \times 10^{11}$ |
| បាច់ប្រូតុង Proton beams | |
| ថាមពលប្រូតុង Energy of protons | $7.00\ \mathrm{TeV}$ |
| ផ្ចិតម៉ាស់ថាមពល Centre of mass energy | $14.0\ \mathrm{TeV}$ |

Table 1: Typical numerical values of relevant LHC parameters.

អ្នករូបវិទ្យាផង់ប្រើឯកតាថាមពល បរិមាណចលនា និងម៉ាសៈ ថាមពលវាស់គិតជា[eV]។ តាមនិយមន័យ $1\ \mathrm{eV}$ គឺជាបរិមាណថាមពលទទួលដោយផង់ដែលមានបន្ទុក e ផ្លាស់ទីឆ្លងកាត់ផលសងប៉ូតង់ស្យែលមួយវ៉ុល

$( 1\ \mathrm{eV} = 1.602 \cdot 10^{-19}\ \mathrm{kg\,m^2 s^{-2}} )$។

បរិមាណចលនាមានខ្នាតគិតជា $\mathrm{eV}/c$ និងម៉ាស់មានខ្នាតគិតជា $\mathrm{eV}/c^2$។ ដែល $c$ ជាល្បឿនពន្លឺក្នុងសុញ្ញកាស។ ដោយ $1\ \mathrm{eV}$ ជាខ្នាតមួយតូច ដូចនេះ គេនិយមប្រើខ្នាតថាមពលប្រើជា MeV $(1\ \mathrm{MeV} = 10^6\ \mathrm{eV})$, GeV $(1\ \mathrm{GeV} = 10^9\ \mathrm{eV})$ or TeV $(1\ \mathrm{TeV} = 10^{12}\ \mathrm{eV})$។

Part A សិក្សាជាមួយសំទុះនៃប្រូតុង រឺអេឡិចត្រុង។

Part B សិក្សាអំពីការកំណត់ឈ្មោះផង់ដែលកើតមានដោយទង្គិចពិសោធន៍នៅ CERN។

## Part A. ឧបករណ៍បង្កើនសំទុះ LHC ( 6 points )

សំទុះ

ឧបមាថាបើប្រូតុងត្រូវបានបង្កើនសំទុះដោយតង់ស្យុង $V$ នោះល្បឿនវាធំក្បែរល្បឿនពន្លឺ។ គេមិនគិតកំហាតផ្សេងៗដោយបន្សាយរស្មី រឺទង្គិចជាមួយផង់ផ្សេងៗទៀត។

| | | |
|---|---|---|
| A.1 | សរសេរកន្សោមត្រឹមត្រូវនៃល្បឿនស្រេច $v$ របស់ប្រូតុងជាអនុមន៍នៃ $V$ និងថេរគ្រឹះ។ | 0.7pt |

គម្រោងពិសោធន៍អនាគតនៅ CERN គឺប្រើប្រូតុងចេញពី LHC អោយវាទង្គិចជាមួយអេឡិចត្រុងមានថាមពល $60.0\ \mathrm{GeV}$។

| | | |
|---|---|---|
| A.2 | ចំពោះផង់មានថាមពលខ្ពស់ និងម៉ាស់ទាប នោះលំងាកធៀប $\Delta = (c-v)/c$ មានតំលៃតូចណាស់។<br>ចូរគណនា $\Delta$ សមស្រប និងគណនា $\Delta$ ចំពោះអេឡិចត្រុងមានថាមពល $60.0\ \mathrm{GeV}$ ដោយប្រើ តង់ស្យុង $V$ និងថេរគ្រឹះ។ | 0.8pt |

ឥឡូវយើងត្រឡប់មកប្រូតុងក្នុង LHC វិញ។ សន្មត់បាច់បំពង់មានរាងជារង្វង់។

| | | |
|---|---|---|
| A.3 | សរសេរកន្សោមចំពោះ $B$ ឯកសណ្ឋានចាំបាច់ដើម្បីរក្សាបាច់ប្រូតុងក្នុងគន្លងវង់។ កន្សោមនេះគួរមានតែថាមពលប្រូតុង $E$, បរិមាត្ររង្វង់ $L$ ថេរគ្រឹះ និងចំនួនលេខ។ អ្នកអាចប្រើតំលៃប្រហែលក្នុងករណីផលទង្គិចតូចជាងលំលៃល្បឿង។<br>ចូរគណនា $B$ ចំពោះ ថាមពលប្រូតុង $E = 7.00\ \mathrm{TeV}$ ដោយមិនគិតអន្តរកម្មរវាងប្រូតុងនិងប្រូតុង។ | 1.0pt |

អានុភាពបន្សាយរស្មី

ផង់មានសំទុះមួយបន្សាយថាមពលក្រោមទំរង់រលកអេឡិចត្រូម៉ាញ៉េទិច។អានុភាពបន្សាយរស្មី $P_{\mathrm{rad}}$ នៃផង់បន្ទុកដែលផ្លាស់ទីដោយល្បឿនមុំថេរ អាស្រ័យនឹងសំទុះរបស់វា $a$, បន្ទុករបស់វា $q$ ល្បឿនពន្លឺ $c$ និង $\varepsilon_0$។

| | | |
|---|---|---|
| A.4 | ប្រើវិធីសាស្ត្រវិភាគវិមាត្រដើម្បីសរសេរកន្សោមអានុភាពរស្មី $P_{\mathrm{rad}}$។ | 1.0pt |

រូបមន្តពិតនៃអានុភាពរស្មីមានកត្តា $1/(6\pi)$ ជាងនេះទៀត ក្នុង relativistic គេបន្ថែម កត្តាមេគុណ $\gamma^4$ ដែល $\gamma = (1 - v^2/c^2)^{-\frac{1}{2}}$.

| | | |
|---|---|---|
| A.5 | គណនាអនុភាពរស្មីសរុប $P_{\mathrm{tot}}$ នៃ LHC ចំពោះ ថាមពលប្រូតុង $E = 7.00\ \mathrm{TeV}$ (Note table 1)។ អ្នកអាចប្រើតម្លៃប្រហែលសមស្រប។ | 1.0pt |

Linear Acceleration:

នៅ CERN ប្រូតុងនៅស្ងៀមត្រូវបានបង្កើនសំទុះដោយ linear accelerator ប្រវែង $d = 30.0\ \mathrm{m}$ ក្រោមតង់ស្យុង $V = 500\ \mathrm{MV}$។ គេចាត់ទុកថាដែនអគ្គិសនីឯកសណ្ឋាន។ linear accelerator ផ្សំឡើងដោយបន្ទះពីរ ដូចបានបង្ហាញក្នុង Figure 1។

| | | |
|---|---|---|
| A.6 | គណនារយៈពេល $T$ ដែលប្រូតុងឆ្លងកាត់ដែននេះ។ | 1.5pt |




Figure 1: Sketch of an accelerator module.

## Part B. កំណត់ឈ្មោះផង់ Particle Identification (4 points)

រយៈពេលហោះ Time of flight:

វាសំខាន់ណាស់ក្នុងការដាក់ឈ្មោះអោយផង់ថាមពលខ្ពស់ដែលកើតដោយទង្គិចក្នុងការបកស្រាយលំនាំអន្តរកម្ម។ វិធីសាស្រ្តងាយស្រួលមួយគឺ វាស់រយៈពេល ($t$) ដែលផង់មួយដោយស្គាល់បរិមាណចលនាចាំបាច់ដើម្បីឆ្លងកាត់ប្រវែង $l$ ហៅថាឧបករណ៍ចាប់សញ្ញា Time-of-Flight (ToF)។ ប្រភេទផង់មួយចំនួនដែលបានកំណត់ឈ្មោះ និង ម៉ាស់របស់វាដោយដោយឧបករណ៍ចាប់សញ្ញានេះមានរាយក្នុង table 2។

| Particle | Mass [MeV/c$^2$] |
|---|---|
| Deuteron | 1876 |
| Proton | 938 |
| charged Kaon | 494 |
| charged Pion | 140 |
| Electron | 0.511 |

Table 2: Particles and their masses.




Figure 2: Schematic view of a time-of-flight detector.

| B.1 | តាងម៉ាស $m$ នៃផង់ជាអនុគមន៍នៃបរិមាណចលនា $p$ ចំងាយ $l$ និងរយៈពេលហោះ $t$ ដោយសន្មត់ថា ផង់មានបន្ទុក $e$ ហើយផ្លាសទីដោយល្បឿនក្បែរៗល្បឿនពន្លឺតាមគន្លងត្រង់ក្នុង ToF detector និង វាផ្លាសទីកែងទៅនឹងប្លង់ detection ទាំងពីរ (មើល figure 2)។ | 0.8pt |
|---|---|---|

| | | |
|---|---|---|
| B.2 | គណនាប្រវែងខ្លីបំផុត $l$ នៃ ToF detector ដែលគេអាចញែក charged kaon ពី charged pion ដោយអោយបរិមាណចលនាវាទាំងពីរមានតំលៃ $1.00\ \mathrm{GeV}/c$។ ការញែកបានល្អគឺវាត្រូវការគំលាតនៃ time-of-flight ធំជាងបីដងនៃកំរិតញែតរបស់ detector។ កំរិតញែកនៃ ToF detector គឺ$150\ \mathrm{ps}\ (1\ \mathrm{ps} = 10^{-12}\ \mathrm{s})$។ | 0.7pt |

ខាងក្រោមនេះ ផង់ដែលបានបង្កើតដោយ LHC detector ត្រូវបានកំណត់ឈ្មោះដោយពីរជំហានគឺ tracking detector និង ToF detector។

Figure 3 បង្ហាញអំពីការដំឡើងក្នុងប្លង់កាត់ទទឹង និងប្លង់កាត់បណ្តោយបាច់ប្រូតុង។ detectors ទាំងពីរជាបំពង់នៅក្នុងតំបន់អន្តរកម្មដែលបាច់ឆ្លងកាត់កណ្តាលបំពង់។ Tracking detector វាស់ផ្លូវចរនៃ charged particle ដែលឆ្លងកាត់ដែនម៉ាញ៉េទិចដែលមានទិសដៅស្របនឹងបាច់ប្រូតុង។

កាំ $r$ នៃគន្លងអោយយើងគណនាបាននូវបរិមាណចលនាទទឹង $p_T$ នៃផង់។

ដោយស្គាល់រយៈពេលទង្គិច ToF detector ត្រូវការតែបំពង់មួយដើម្បីវាស់រយៈពេលហោះ។ បំពង់ ToFនេះ វាស្ថិតនៅខាងក្រៅ tracking chamber។

ក្នុងលំហាត់នេះ អ្នកអាចសន្មត់ថាគ្រប់ផង់ដែលបង្កើតដោយទង្គិចវាកែងទៅនឹងបាច់ប្រូតុងគឺផង់ដែលកើតឡើងគ្មានបរិមាណចលនាបណ្តោយបាច់ប្រូតុងទេ




transverse plane

cross section of the longitudinal view at the center of the tube along the beamline

( 1 ) - ToF tube
( 2 ) - track
( 3 ) - collision point
( 4 ) - tracking tube
( 5 ) - proton beams
⊗ - magnetic field

Figure 3 : Experimental setup for particle identification with a tracking chamber and a ToF detector. Both detectors are tubes surrounding the collision point in the middle. Left : transverse view perpendicular to the beamline. Right : longitudinal view parallel to the beam line. The particle is travelling perpendicular to the beam line.

| B.3 | តាងម៉ាស់ផង់ជាអនុគមន៍នៃ $B$, $R$ បំពង់ ToF ថេរត្រី៖ និងទំហំដែលដែលបានវាស់រួច: $r$ និង $t$។ | 1.7pt |
|---|---|---|

យើងរកឃើញផង់ចំនួនបួន និងត្រូវដាក់ឈ្មោះអោយវា។ ដោយ $B = 0.500\ \mathrm{T}$ ហើយ $R$ ស្មើ $3.70\ \mathrm{m}$ ។ ខ្នាតនៃរង្វាស់ ( $1\ \mathrm{ns} = 10^{-9}\ \mathrm{s}$ ):

| Particle | Radius of the trajectory $r$ $[\mathrm{m}]$ | Time of flight $t$ $[\mathrm{ns}]$ |
|---|---|---|
| A | 5.10 | 20 |
| B | 2.94 | 14 |
| C | 6.06 | 18 |
| D | 2.31 | 25 |

| | | |
|---|---|---|
| B.4 | កំណត់ឈ្មោះនៃផង់ទាំងបួនដោយគណនាម៉ាស់របស់វា។ | 0.8pt |